ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទ សហគមន៍ជីក្រែង

## សម្រាប់រយៈពេល ៣ ឆ្នាំ (២០១៧ - ២០១៩)

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | ជីក្រែង |
| ភូមិ | ៖ | ១៤ ភូមិ |
| ឃុំ | ៖ | ជីក្រែង |
| ស្រុក | ៖ | ស្រុកជីក្រែង |
| ខេត្ត | ៖ | សៀមរាប |

ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៦

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទ
# សហគមន៍ជីក្រែង
## សម្រាប់រយៈពេល ៣ ឆ្នាំ
## (២០១៧ - ២០១៩)

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | ជីក្រែង |
| ភូមិ | ៖ | ១៤ ភូមិ |
| ឃុំ | ៖ | ជីក្រែង |
| ស្រុក | ៖ | ស្រុកជីក្រែង |
| ខេត្ត | ៖ | សៀមរាប |

ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ ២០១៦

# មាតិកា


១.ស្ថានភាពទូទៅ.............................................................................................៤
២.អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម ..........................................................................៥
ក.ប្រជាសាស្ត្រ..........................................................................................៥
ខ. មុខរបរ ..............................................................................................៥
៣.កន្លែងនេសាទ និង ធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍ ..........................៦
ក. ទីតាំង ................................................................................................៦
ខ. ដែននេសាទ...........................................................................................៦
ខ.១.បឹង ...............................................................................................៦
ខ.២.អូរ/ស្ទឹង ..........................................................................................៦
ខ.៣.ត្រពាំង ............................................................................................៧
គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ..................................................៨
ឃ. ធនធានជលផល ......................................................................................៩
១.ប្រភេទត្រី .............................................................................................៩
២.ប្រភេទវារីសត្វ.........................................................................................៩
៣.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ.........................................................១០
៤.ការធ្វើនេសាទ ...........................................................................................១០
ក.អ្នកនេសាទ ............................................................................................១០
ខ.ឧបករណ៍នេសាទ ....................................................................................១១
គ.ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ..........................................................១២
៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍......................................................................១២
ក.ទស្សនៈវិស័យ ...........................................................................................១២
ខ.គោលបំណង.............................................................................................១២
គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ....................................................................១២
គ.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ......................................................................១៤
គ.២. ផែនការកែលម្អដែននេសាទ ...............................................................................១៦
គ.៣. ផែនការរៀបចំកន្លែងអភិរក្ស .............................................................................១៥
គ.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក ..............................................................................១៦
គ.៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម..............................................................................១៧
គ.៦. ផែនការថវិកាទ្រទ្រង់សម្រាប់ការអភិវឌ្ឍន៍សហគមន៍ ...................................................១៨
គ.៧.ផែនការផ្សេងៗ...............................................................................................១៩
គ.៧.១.ផែនការផ្សព្វផ្សាយពីច្បាប់ជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធ....................................១៩
គ.៧.២. ផែនការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព.........................................................២០

គ.៧.៣. ផែនការអភិវឌ្ឍន៍កម្មវិធីចំរុះ..........ទំព័រ ២០

គ.៧.៤.ផែនការជួសជុលស្នាក់ការសហគមន៍ ..........២១

ឃ. យុទ្ធសាស្ត្រ..........២១

៦.ឧបសម្ពន្ធ

ឧបសម្ពន្ធ ៖តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ឆ្នាំ២០១៧-២០១៩..........២៣

ឧបសម្ពន្ធ ៖តារាងកម្មវិធីការងារឆ្នាំ២០១៧-២០១៩ ..........២៧

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ជីក្រែង

**១- ស្ថានភាពទូទៅ**

នៅឆ្នាំ២០០០ រដ្ឋបាលជលផលបានធ្វើកំណែទម្រង់ ដើម្បីឲ្យស្របជាមួយគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដែលផ្តោតលើការកាត់បន្ថយភាពក្រីក្រដោយផ្ទេរសិទ្ធអំណាចដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ជនបទ ឲ្យចូលរួមចូលរួមគ្រប់គ្រងធនធានជលផលនៅមូលដ្ឋានរបស់ខ្លួនប្រកបដោយនិរន្តភាព និងសមធម៌តាមបែបសហគមន៍នេសាទ ក្នុងគោលបំណងទទួលផលប្រយោជន៍ និងធ្វើឲ្យធនធានជលផលឲ្យប្រសើរឡើងក្នុងមូលដ្ឋានរបស់ខ្លួន ។ កន្លងមកឃុំជីក្រែងត្រូវបានរៀបចំសហគមន៍នេសាទដោយមានការចូលរួមយ៉ាងកុះករពីប្រជាពលរដ្ឋមូលដ្ឋាន និងបានការគាំទ្រពីគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប ជំនាញជលផល និងសហការពីអាជ្ញធរដែនដី ។ ដូចេនះ សហគមន៍នេសាទជីក្រែង ត្រូវបានបង្កើតឡើងដោយមហាសន្និបាតលើកដំបូងនៅថ្ងៃទី០៥ ខែមិនា ឆ្នាំ២០០១ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍លើកទី២នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៤ ដែលបានរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដោយបានអនុវត្តចាប់ពីឆ្នាំ ២០០៨ ដល់ ២០១០ ព្រមទាំងត្រូវបានក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទប្រកាសទទួលស្គាល់នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ ។ សហគមន៍នេសាទជីក្រែង នឹងបច្ចុប្បន្នភាព និងរៀបចំលើកទី ២ នៅថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០១៦ ដោយមានចូលរួមពីសមាជិកគណៈកម្មសហគមន៍នេសាទ ប្រជាពលរដ្ឋ មេភូមិពាក់ព័ន្ធ ក្រុមប្រឹក្សា ជាពិសេសបានការគាំទ្របច្ចេទេស និងថវិកាពីរដ្ឋបាលជលផលថ្នាក់កណ្តាល និងសម្របសម្រួលដោយខណ្ឌរដ្ឋបាលជលផលសៀមរាប ។

គណៈកម្មការសហគមន៍នេសាទត្រូវបានបោះឆ្នោតចំនួន ០៣ អណ្តត្តិ រហូតមកដល់ពេលបច្ចុប្បន្ន ព្រមទាំងបានអនុវត្តភារៈកិច្ចរបស់ខ្លួនដែលស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍ និងកិច្ចព្រមព្រៀងកន្លែងនេសាទ។ ទន្ទឹមនឹងនេះផងដែរ គណៈកម្មការសហគមន៍នេសាទ ត្រូវបានកសាងសមត្ថភាពតាមរយៈការចូលរួមបណ្តុះបណ្តាល សិក្ខាសាលា ប្រជុំបណ្តាញការងារ និងទស្សនៈកិច្ចសិក្សា និងរៀនសូត្រតាមឯកសារផ្សេងៗ ។

ដូច្នេះ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ជីក្រែង បានធ្វើការកែសម្រួលសកម្មភាពសំខាន់ៗខ្លះ និងថវិកាដែលគ្រោង ដើម្បីអាចធានាដល់ការគ្រប់គ្រងធនធានជលផលនៅក្នុងអភិរក្ស នេសាទសហគមន៍ តំបន់អភិរក្ស ព្រមទាំងប្រជាពលរដ្ឋមូលដ្ឋានទទួលបានផលប្រយោជន៍ពីធនធានជលផលប្រកបដោយនិរន្តភាព និងសមធម៌។

## ២. អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ចសង្គម

### ក. ប្រជាពលរដ្ឋ

នៅពេលបច្ចុប្បន្ន ក្នុងឃុំនេះមានចំនួន ១៤ ភូមិ ប្រជាពលរដ្ឋសរុបចំនួន ១៧២២ គ្រួសារដែលគ្រប់ដណ្តប់សហគមន៍នេសាទជីក្រែង។ ចំនួនគ្រួសារដែលចូលជាសមាជិកសហគមន៍នេសាទមានចំនួន ៩០១ គ្រួសារ មានចំនួន ២៧០៣ នាក់ ក្នុងនោះស្ត្រីមានចំនួន ១១៣០ នាក់ ។

សហគមន៍នេសាទជីក្រែងគោរពព្រះពុទ្ធសាសនា ដែលមានស្ថានភាពដូចជា៖

- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ៨៥ នាក់
- ចំនួនបុរសពោះម៉ាយក្នុងសហគមន៍នេសាទមាន ១៥ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមានប្រុស ១៥ នាក់ ក្នុងនោះស្ត្រីមានចំនួន ០៧នាក់

- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទ ១១ នាក់ ក្នុងនោះកុមារីមានចំនួន ០៥ នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ២២ នាក់ក្នុងនោះស្ត្រីមានចំនួន ០៩ នាក់
- ចំនួនអ្នកមានជម្ងឺរាំរ៉ៃក្នុងសហគមន៍នេសាទមាន ០៩ នាក់ ក្នុងនោះស្ត្រីមានចំនួន ០៤ នាក់
- សាលារៀនមានសិស្សសរុបចំនួន ៣១១ នាក់ ក្នុងនោះកុមារីមានចំនួន ១៥៩ នាក់
- តាមរបាយការណ៍របស់ក្រុមប្រឹក្សាឃុំដីក្រែងបានបង្ហាញថា៩៥នាក់ដែលមិនចេះអក្សរក្នុងស្ត្រីចំនួន២៧នាក់

### ខ.សេដ្ឋកិច្ចសង្គម

តាមរបាយការណ៍ និងឯកសារព័ត៌មានឃុំឆ្នាំ ២០១៦ បានបញ្ជាក់ថា នៅក្នុងសហគមន៍ដីក្រែង មានប្រជាពលរដ្ឋសរុបចំនួន ១៧២២ គ្រួសារ បានពឹងផ្អែកលើការធ្វើស្រែជាចំបង រីឯការនេសាទដើរតួនាទីបន្ទាប់ពីការធ្វើស្រែ ក្រៅពីនេះសកម្មភាពបន្ទាប់បន្សំមានការចិញ្ចឹមសត្វ លក់ដូរ ការចិញ្ចឹមត្រី និងធ្វើជាកម្មករជាដើម ។ ការគាំទ្រមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ ជាសកម្មភាពចំបងដែលជួយពង្រីកមុខរបរដល់ប្រជានេសាទនៅក្នុងសហគមន៍ ជាពិសេស បានជួយកាត់បន្ថយសម្ពាធនៃការធ្វើអាជីវកម្មលើធនធានជលផលហួសកំរិត។

ពេលបច្ចុប្បន្ន នៅក្នុងសហគមន៍នេសាទដីក្រែង ប្រជាពលរដ្ឋមានស្ថានភាពនៃការចិញ្ចឹមជីវិត និងមុខរបរសំខាន់ៗរួមមាន៖

- អ្នកដែលមានមុខរបរពឹងផ្អែកលើការនេសាទស្ទើតែទាំងស្រុកមានចំនួន ៤៥ គ្រួសារ
- អ្នកដែលមានមុខរបរធ្វើស្រែជាចំបង និងមុខរបរបន្ទាប់បន្សំមានចំនួន ១៦៤០ គ្រួសារ
- ប្រមូលទិញ និងលក់ត្រី មានចំនួន ៣ គ្រួសារ
- អ្នកចិញ្ចឹមត្រី និងនេសាទ មានចំនួន ១៨ គ្រួសារ (ត្រីរ៉ស ត្រីប្រា និងទីឡាបព្យា)
- កម្មករ និងនេសាទមានចំនួន ៣៥ គ្រួសារ
- ជាងផ្ទះ ចំនួន ០៤ គ្រួសារ
- គ្រូបង្រៀន និងនេសាទ ១៥ នាក់ និង
- អ្នកលក់ដូរ ៤៧ គ្រួសារ។

## ៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ

### ក. ទីតាំង

សហគមន៍នេសាទដីក្រែងមានទីតាំងស្ថិតក្នុងភូមិដីក្រែង ដែលជាដែននេសាទសាធារណៈរបស់រដ្ឋដែលពីអតីតកាលគឺជាឡូត៍នេសាទលេខ ០៦ និងលេខ ០៧ នៃដែននេសាបទឹកសាបក្នុងខេត្តសៀមរាប។ កន្លែងនេសាទសហគមន៍ដីក្រែងមានទំហំ ១១,៥៨៦ ហិកតា ហើយមានកន្លែងអភិរក្សពូជត្រីសំខាន់ៗចំនួន ០២ កន្លែង គឺ បឹងកំផែន និងកំពីងបឹងមានទំហំប្រហែល ៦០ ហិចតា និងខ្សែងស្ទឹងកំបុត មានទំហំប្រហែល ១៥ ហិចតា ។ ទីតាំងទាំងនេះ ត្រូវបានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង និងក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទប្រកាសទទួលស្គាល់នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ ។ ដូចនេះ សហគមន៍នេសាទ

ដីក្រែងមានព្រំប្រទល់ជាប់នឹង៖

- ខាងជើងទល់នឹង ឃុំសង្វើយ ស្រុជីក្រែង
- ខាងត្បូងទល់នឹង ខ្សែងស្ទឹងកំបុត ផ្លូវលក ឃុំអន្លង់សំណរ
- ខាងកើតទល់នឹង ស្ទឹងទំនប់សូងខាងលិច ឃុំអន្លង់សំណរ
- ខាងលិចទល់នឹង ព្រំប្រទល់ឃុំសង្វើយ ឃុំសង្វើយ ។

## ខ.ដែននេសាទ

កន្លែងនេសាទសហគមន៍នេសាទដីក្រែង បានផ្តល់លក្ខណៈងាយស្រួលដល់ការរស់នៅប្រជាពលរដ្ឋក្នុងសហគមន៍នេះ មិនតែប៉ុណ្ណោះ សហគមន៍អាចធ្វើដំណើរឆ្លងកាត់តាមទូក ការណ្ហូត ជាពិសេស ចរាចររបស់ត្រី និងវារីសត្វគ្រប់ប្រភេទនៅគ្រប់រដូវ។ កន្លែងនេសាទសហគមន៍នេសាទដីក្រែងតភ្ជាប់ជាមួយ អូរ ស្ទឹង ប្រឡាយ និងបឹង សំខាន់ៗ ដូចជា៖

### ខ.១ បឹង

| ល.រ | ឈ្មោះបឹង | ទំហំជា ហត | រដូវនេសាទ |
|---|---|---|---|
| ១ | បឹងវែង | ១៧,១០ | ខែ ០១ - ខែ ១២ |
| ២ | បឹងផុក | ៦,២៨ | ខែ ០១ - ខែ ១២ |
| សរុប | | ២៣,៣៨ | |

### ខ.២.អូរ/ស្ទឹង

| ល.រ | ឈ្មោះអូរ/ស្ទឹង | ទំហំជា ហត | រដូវនេសាទ |
|---|---|---|---|
| ១ | អូរសេកដេក | ៩,១៦ | ខែ ០១ - ខែ ១២ |
| ២ | អូរច្រវាល្មៀស | ៣,៧៣ | ខែ ០១ - ខែ ១២ |
| ៣ | អាវែងអាក្រមោល | ៣,៥០ | ខែ ០១ - ខែ ១២ |
| សរុប | ១៦,៣៩ | | |

### ខ.៣.ត្រពាំង

| ល.រ | ឈ្មោះត្រពាំង | ទំហំជា ហត | រដូវនេសាទ |
|---|---|---|---|
| ១ | ត្រពាំងគ្រួស | ៦,៩០ | ខែ ០១ - ខែ ១២ |
| ២ | ត្រពាំងកក់ | ៣,៥៧ | ខែ ០១ - ខែ ១២ |
| ៣ | ត្រពាំងតាប្រាក់ | ៣,៣០ | ខែ ០១ - ខែ ១២ |
| ៤ | ត្រពាំងទទឹងថ្ងៃ | ៣,៣០ | ខែ ០១ - ខែ ១២ |
| ៥ | ត្រពាំងបឹងនួន | ២,៦០ | ខែ ០១ - ខែ ១២ |
| ៦ | ត្រពាំងគេដាំឈូក | ២,៥៣ | ខែ ០១ - ខែ ១២ |
| ៧ | ត្រពាំងស្វែងតាន់ | ២,៤០ | ខែ ០១ - ខែ ១២ |
| ៨ | ត្រពាំងចក | ១,៨០ | ខែ ០១ - ខែ ១២ |
| ៩ | ត្រពាំងស្មោញ | ១,១០ | ខែ ០១ - ខែ ១២ |
| ១០ | ត្រពាំងក្រែង | ០,៥០ | ខែ ០១ - ខែ ១២ |
| ១១ | ត្រពាំងក្របៅ | ០,៤០ | ខែ ០១ - ខែ ១២ |
| ១២ | ត្រពាំងក្របីច្រើន | ០,៣០ | ខែ ០១ - ខែ ១២ |
| សរុប | ២៨,៦០ | | |

កន្លែងនេសាទសហគមន៍ដីក្រែង មានបឹងចំនួន ០២ ព្រែក ដែលមានទំហំប្រមាណ ២៣,៣៨ ហិកតា អូរ/ស្ទឹងចំនួន ០៣ អូរ/ស្ទឹង ដែលមានទំហំប្រមាណ ១៦,៣៩ ហិកតា និងត្រពាំងមានចំនួន ១២ ត្រពាំងដែលមានទំហំប្រមាណ ២៨,៦០ ហិកតា ព្រៃលិចទឹកមានទំហំសរុប ៨.៣៨៤ ហិកតា តំបន់វាលស្មៅមានទំហំប្រមាណ ៣៣៨ ហិកតា និងកន្លែងអភិរក្សចំនួន ០២ កន្លែងគឺ បឹងកំផែន និងកំពីងបឹង និងខ្វែងស្ទឹងកំបុត ដែលជាកន្លែងមានសក្តានុពលសម្រាប់អភិរក្សត្រីមេពូជមានទំហំសរុប ៧៥ ហិកតា ផ្ទៃដែននេសាទសហគមន៍នេសាទដែលមិនរាប់បញ្ចូលខាងលើមានប្រមាណ ២៧៦០,៦៣ ហិកតា។ ដូចនេះ ផ្ទៃដែននេសាទសហគមន៍នេសាទ មានទំហំសរុប ១១.៥៨៦ ហិចតា ។

## គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

ទោះបីប្រជាពលរដ្ឋក្នុងសហគមន៍នេសាទដីក្រែងភាគច្រើនជាកសិករក៏ដោយ តែផលត្រីនៅតែជាអាហារសំខាន់សម្រាប់គាំទ្រដល់ការចិញ្ចឹមប្រចាំថ្ងៃរបស់ពួកគាត់ ។ ដូចនេះ កំណើនប្រជាពលរដ្ឋក្នុងតំបន់ និងអ្នកនេសាទខាងក្រៅ អាចជាផលប៉ះពាល់ជាអវិជ្ជមានដល់ជីវភាពក្នុងសហគមន៍នេះ ប្រសិនបើគ្មានវិធានក្នុងការបង្ក្រាបបទល្មើសនេសាទ។ ផ្អែកតាមពិគ្រោះយោបល់ជាមួយ សហគមន៍នេសាទដីក្រែង និងអាជ្ញាធរមូលដ្ឋាន ក្រោមការសម្របសម្រួលពីរដ្ឋបាលជលផលថ្នាក់ កណ្តាល និងខណ្ឌរដ្ឋបាលជលផលសៀមរាប សហគមន៍នេសាទដីក្រែងបានសម្រេចរក្សាទុក កន្លែងអភិរក្សចំនួន ០២ កន្លែងដែលបានកំណត់រួចកាលពីធ្វើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដីក្រែង ឆ្នាំ ២០០៨ ដល់ ឆ្នាំ ២០១០ ដែលមានដូចជា បឹងកំផែន និងកំពីងបឹង និងខ្វែងស្ទឹងកំបុត ដែលជាកន្លែងមានសក្តានុពលសម្រាប់អភិរក្សត្រីមេពូជ ។ ដូចនេះផងដែរ កន្លែងអភិរក្សបានធ្វើការគ្រប់គ្រងបន្ទាប់ពីសហគមន៍នេសាទដីក្រែង ត្រូវបានប្រកាសទទួលស្គាល់ដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ហើយកន្លែងអភិរក្សត្រីមេពូជទាំងពីរមានដូចខាងក្រោម៖

| ល.រ | ឈ្មោះអន្លង់ | ទំហំជា ហត | ការអភិរក្ស |
|---|---|---|---|
| ១ | បឹងកំផែន និងកំពីងបឹង | ៦០ | កន្លែងអភិរក្សត្រីមេពូជ |
| ២ | ខ្វែងស្ទឹងកំបុត | ១៥ | កន្លែងអភិរក្សត្រីមេពូជ |
| សរុប | ៧៥ | | |

## ឃ.ធនធានជលផល

### ១.ប្រភេទត្រី៖

នៅក្នុងប្រទេសកម្ពុជា ធនធានជលផលបានដើរតួនាទីយ៉ាងសំខាន់ក្នុងសន្តិសុខស្បៀង ដោយឡែកត្រីអាចផ្តល់ជាអាហារដល់ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋប្រចាំថ្ងៃ ។ តាមការបង្ហាញពីសហគមន៍ដីក្រែងបានឲ្យដឹងថាពេលបច្ចុប្បន្ន ធនធានជលផលបានថយចុះជាពិសេស ក្នុងឆ្នាំ ២០១៥ ដោយសារមានការប្រែប្រួលអាកាសធាតុដែលធ្វើឲ្យបឹង និងព្រែករីងរាក់ ហើយធ្វើឲ្យប្រភេទត្រីមេពូជត្រូវបាននេសាទយកស្ទើរតែទាំងអស់ ។ ផ្អែកតាមការអង្កេតរបស់ក្រុមការងារ និងសមាជិកសហគមន៍ ធនធានជលផលក្នុងសហគមន៍នេសាទដីក្រែងមានដូចជា៖

### ឃ.១.ប្រភេទត្រី:

ក្នុងសហគមន៍នេសាទដីក្រែងមានប្រភេទត្រីដូចជា៖ ត្រីរៀល ត្រីឆ្លាំង ត្រីកេះ ត្រីកញ្ចុះ ត្រីអាចម៍កុក ត្រីឆ្អែក ត្រីគ្រំ ត្រីចិន ត្រីឆ្ពិន ត្រីកន្ធប់ ត្រីក្រសក់ ត្រីក្រាយ ត្រីក្រម៉ម ត្រីខ្នឹង ត្រីរ៉ស់ ត្រីឆ្តោ ត្រីអណ្តែង ត្រីឆ្លូញ ត្រីចេកទុំ ត្រីកន្ធង ត្រីឆ្តោក ត្រីកញ្ចុះភ្លោង ត្រីក្រពត ត្រីចង្វា ត្រីដំរី ត្រីកំភ្លៀញ ត្រីផ្ទក់ ត្រីអណ្តាតឆ្កែ ត្រីឆ្ពៀត ត្រីឆ្លាំងហាយ ត្រី

ក្រាញ់ ត្រីព្រួល ត្រីស្លាបមាន់ ត្រីសង្កត់ប្រាក់ ត្រីក្រុះ ត្រីព្រួល ត្រីស្លាត ត្រីស្រកាក្តាម ត្រីកំភ្លៀវ ត្រីខ្មាន់ ត្រីគ្រំ ត្រីដៀប ត្រីចង្វាមូល ត្រីឆ្លាំងហាយ ត្រីក្អែក ត្រីលិញ ។ល។

**ឃ.២.ប្រភេទវារីសត្វ៖**

ក្នុងសហគមន៍នេសាទជីក្រែង មានប្រភេទវារីសត្វដូចជា៖ ក្តាម ខ្យង ខ្ចៅ គ្រុំ លៀស អណ្តើក កន្ធាយ ពស់កង្កែប ហ៊ីង គីង្គក់ អន្ទង់ ក្តាមទូក កន្ធេះឡង់ ក្រពើត្រី អន្សង់ គេ សត្វស្វាក្រះ សំពោច ។ល។

**ឃ.៣.ប្រភេទបក្សី៖**

ក្នុងសហគមន៍នេសាទជីក្រែង មានប្រភេទបក្សីដូចជា៖ ក្អែកទឹក សត្វក្រៀល សត្វប្រវឹក សត្វក្រសា សត្វកុកសសត្វមាន់ទឹក សត្វទាព្រៃ សត្វទាទឹក សត្វអូត សត្វសេក សត្វចាប សត្វរនាលខ្យង ។ល។

**ឃ.៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ៖**

ក្នុងសហគមន៍នេសាទជីក្រែង មានប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិដូចជា៖ ដើមរាំងទឹក ដើមតាអូរដើមអញ្ចាញ ដើមថ្វាន់ ដើមកន្សែង ដើមបន្លាយួន ដើមស្វាចទឹក ដើមកណ្តាប់ចង្កេរ ដើមរំដេញ ដើមបន្លាស្អិត ដើមប្រកែង ។ល។

**៤-ការធ្វើនេសាទ៖**

នេសាទ ជាមុខរបរបន្ថែមសម្រាប់ការចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់សមាជិកសហគន៍ជីក្រែង និង ផលត្រីត្រូវបានប្រើប្រាស់ផ្ទាល់ក្នុងតំបន់ និងលក់ដូរនៅទីផ្សារក្នុងស្រុកផ្ទាល់ដើម្បីរកចំណូលជួយគ្រួសារ ។ ពេលបច្ចុប្បន្ន ប្រជាពលរដ្ឋទាំងអស់ក្នុងសហគន៍នេះបាននេសាទ ដោយបានប្រើប្រាស់ឧបករណ៍លក្ខណៈគ្រួសារ ស្របតាមលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង ផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍ ជាពិសេសផែនការគ្រប់គ្រងរបស់សហគមន៍ដែលបានរៀបចំសម្រាប់ឆ្នាំ២០០៨ដល់ ឆ្នាំ២០១០។ ទោះបីជាយ៉ាងនេះក្តី នៅមានជនល្មើសខ្លះ បានប្រើប្រាស់ឧបករណ៍ខុសច្បាប់នៅលើកន្លែងនេសាទសហគមន៍ជីក្រែង ជាពិសេស នៅក្នុងកំឡុងឆ្នាំ ២០១៥ ដែលមានបញ្ហាគ្រោះរាំងស្ងួតបានធ្វើឲ្យបឹង ព្រែក និងត្រពាំងបារីងរាក់ ហើយប្រភេទត្រីមេពូជបាននេសាទដោយជនល្មើស ។

តាមការសិក្សា និងប្រមូលទិន្នន័យពីក្រុមប្រឹក្សាឃុំ ភូមិពាក់ព័ន្ធ និងសហគមន៍ជីក្រែង បានបង្ហាញពីចំនួនអ្នកដែលពាក់ព័ន្ធក្នុងការធ្វើនេសាទលើកន្លែងនេសាទសហគមន៍មានដូចខាងក្រោម៖

**៤.ក.អ្នកនេសាទ**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ៩០១ គ្រួសារ មានចំនួន ២៧០៣ នាក់ ក្នុងនោះស្ត្រីមានចំនួន ១១៣០ នាក់ ។
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍ជីក្រែងមានចំនួន ៨២១ គ្រួសារ ក្នុងនោះមនុស្សសរុបចំនួន ២៤៦៣ នាក់ ស្ត្រីមានចំនួន ១៣៣៥ នាក់ ។
- តាមការប៉ាន់ស្មានអ្នកនេសាទដែលមកពីខាងក្រៅ ហើយមិនមែនជាសមាជិកដែលជាសហគមន៍ជីក្រែងមានប្រហែល ២៨៥ គ្រួសារ ក្នុង១ឆ្នាំ ។

## ៤.ខ.ឧបករណ៍នេសាទ

នៅរដូវបើកនេសាទ ប្រជាជននៅក្នុងសហគមន៍នេសាទដីក្រែង និងអ្នកខាងក្រៅតែងតែធ្វើនេសាទដោយប្រើប្រាស់ប្រភេទឧបករណ៍នេសាទលក្ខណៈគ្រួសារដូចជា៖ លប មង សន្ទូច ។ល។ ដូចនេះផងដែរ សមាជិក និងគណៈកម្មការសហគមន៍នេសាទដីក្រែង បានធ្វើការប៉ាន់ប្រមាណពីតម្រូវការប្រភេទឧបករណ៍នេសាទដែលស្របតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍ និងផែនការគ្រប់គ្រង ជាពិសេស សមាជិក និងគណៈកម្មការសហគមន៍នេសាទដីក្រែង ទាមទារសមត្ថកិច្ចជំនាញជលផលធ្វើការផ្សព្វផ្សាយច្រើនដងដល់ប្រជាពលរដ្ឋក្នុសហគមន៍ និងអ្នកនសាទខាងក្រៅ លើប្រភេទឧបករណ៍នេសាទដែលហាមឃាត់ដូចជា ឧបករណ៍ឆក់ត្រី អ៊ុយស្បៃមុង ។ល។

ឧបករណ៍នេសាទ និងទូកម៉ាស៊ីន របស់សមាជិកសហគមន៍នេសាទ ដែលប្រើប្រាស់ក្នុងសហគមន៍ដីក្រែង ដូចជា៖

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ/គ្រួសារ | ចំនួនគ្រួសារ | រដូវនេសាទ |
|---|---|---|---|---|---|
| ១ | មងរាយ | ម៉ែត្រ | ២០០ម x១,៥ម x០,០៣៥ម | ៥០ | ខែ ១០ ដល់ ខែ ១២ |
| ២ | សន្ទូចរនង | ផ្លែ | ៥០០ ផ្លែ | ៥៨ | ខែ ១០ ដល់ ខែ ១២ |
| ៤ | លបព្រៀង | លប | ២៥ | ៧៥ | ខែ ១០ ដល់ ខែ ១២ |
| ៦ | ដាក់លាន់ | លាន់ | ៦៥ | ៥៥ | ខែ ០១ ដល់ ខែ ១២ |
| ៧ | លបកំភ្លាញ | ម៉ែត្រ | ៣៥ | ៦៥ | ខែ ១០ ដល់ ខែ ១២ |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|
| ទូកម៉ាស៊ីន Hynota | ៥៥ | ៦០០ | ៦ និង១៨ |
| ទូកម៉ាស៊ីន Ugohama | ២៥ | ៥០០ | ៦,៥ |
| ទូកម៉ាស៊ីន Cava | ២០ | ៤០០ | ៦ |
| ទូកអុំ ឬទូកចែវ | ២៨ | ១០០ | |

ឧបករណ៍នេសាទ និងទូកម៉ាស៊ីន របស់អ្នកក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ទំហំ/ប្រវែង/គ្រួសារ | ចំនួនគ្រួសារ | រដូវនេសាទ |
|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ២០០ម x១,៥ម x០,០៣៥ម | ២៥ | ខែ ១០ ដល់ ខែ ១២ |
| សន្ទូចរនង | ផ្លែ | ៥០០ ផ្លែ | ២០ | ខែ ១០ ដល់ ខែ ១២ |
| លបព្រៀង | លប | ២៥ | ៥០ | ខែ ១០ ដល់ ខែ ១២ |
| ដាក់លាន់ | លាន់ | ២៥ | ៧០ | ខែ ០១ ដល់ ខែ ១២ |
| លបកំភ្លាញ | ម៉ែត្រ | ២០ | ១៥ | ខែ ១០ ដល់ ខែ ១២ |

| ប្រភេទទូកម៉ាស៊ីន | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|
| កាណូតម៉ាស៊ីន Hynota | ៧ | ៥០០ | ៦ |
| កាណូតម៉ាស៊ីន Honda | ១៥ | ៤០០ | ២០ ដល់ ៣៥ |
| កាណូត Cava | ១១ | ២០០ | ១,៥០ |
| ទូកអុំ ឬទូកចែវ | ១៥ | ១០០ | |

ឧបករណ៍នេសាទ និងកាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីខាងក្រៅសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ទំហំ/ប្រវែង/គ្រួសារ | ចំនួនគ្រួសារ | រដូវនេសាទ |
|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ២០០ម x១,៥ម x០,០៣៥ម | ១៥ | ខែ ១០ ដល់ ខែ ១២ |
| សន្ទូចរនង | ផ្លែ | ៥០០ ផ្លែ | ១២ | ខែ ១០ ដល់ ខែ ១២ |
| ទ្រូព្រៀង | លប | ២៥ | ២៥ | ខែ ០៧ដល់ ខែ ០២ |
| ដាក់លាន់ | លាន់ | ៦៥ | ២០ | ខែ០៧ ដល់ ខែ ០២ |
| លបកំភ្លាញ | ម៉ែត្រ | ៣៥ | ៤ | ខែ ១០ ដល់ ខែ ១២ |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|
| កាណូតម៉ាស៊ីន Hynota | ៤ | ៥០០ | ៦ និង១៨ |
| ទូកម៉ាស៊ីន Honda | ១១ | ៥០០ | ១៦០ ១៨០ |
| ទូកម៉ាស៊ីន Cava | ៦ | ៤០០ | ១៦ |
| ទូកអុំ ឬទូកចែវ | ១៥ | ១០០ | |

### គ.ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គិតជា គក្រ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីគ្រប់ប្រភេទ | ៥៣៥០ | ៧៥០០ | ១២៨៥០ |
| ក្តាម ខ្យង ខ្ចៅ និងលៀស | ១៥០ | ៦៥០ | ៨០០ |
| អន្ទង់ | ៥៥០ | ៧៥០ | ១៣០០ |
| សរុប | ៦០៥០ | ៨៩០០ | ១៤៩៥០ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក.ទស្សនៈវិស័យ

សហគមន៍នេសាទជីក្រែង មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តភាព និងសមធម៌ ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ.គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបជាកន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ ទំនាបលិចទឹកក្នុងរដូវទឹកជំនឡើង ព្រៃលិចទឹក និងកន្លែងអន្លង់អភិរក្ស។
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឲ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទតាមរយៈការអភិវឌ្ឍចំរុះដោយមានការចូលរួម
- ដើម្បីឲ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

## គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
### គ.១ ផែនការប្រើប្រាស់ឧបករណ៍នេសាទ:
### គោលបំណង

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ដីក្រហមគឺ រៀបចំឡើងដោយបានគិតគូរអំពីប្រភេទដែននេសាទ ប្រភេទទំហំ ប្រវែង ចំនួនឧបករណ៍នេសាទចំនួនអ្នកនេសាទ រដូវនេសាទ និងការប៉ាន់ប្រមាណផលស្តុកដែលមាននៅក្នុងដែននេសាទ ដោយធ្វើយ៉ាងណាមិនឲ្យការធ្វើនេសាទលើសពីតម្រូវការធនធានជលផល ដែលមានក្នុងកន្លែងសហគមន៍នេសាទ។

**ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទត្រូវបានរៀបចំឡើងដូចខាងក្រោម:**

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|
| ១ | មងរាយ | ម៉ែត្រ | ២០០ម x១,៥ម x០,០៣៥ម | ខែ ១០ ដល់ ខែ ១២ |
| ២ | សន្ទូចរនង | ផ្លែ | ៥០០ ផ្លែ | ខែ ១០ ដល់ ខែ ១២ |
| ៣ | ដាក់លាន់ | លាន់ | ៦៥ | ខែ ០១ ដល់ ខែ ១២ |
| ៤ | លបកំភ្លាញ | ម៉ែត្រ | ៣៥ | ខែ ១០ ដល់ ខែ ១២ |
| ៦ | សំណាញ់ | វង់ | ១ | ខែ ០១ ដល់ ខែ ០៤ |

| ល.រ | ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឲ្យប្រើ | | |
|---|---|---|---|---|---|
| | | | ប្រភេទ | ទំហំ/ប្រវែង/គ្រួសារ | គ្រួសារ |
| ១ | បឹងវែង | ខែ០៨-ខែ០២ | សន្ទូច មង លប | ២៥លប/១០០ម/១០០ផ្លែ | ៣០ |
| ២ | បឹងផុក | ខែ០៨-ខែ០២ | សន្ទូច មង លប | ២៥លប/១០០ម/១០០ផ្លែ | ៣៥ |
| ៣ | អូរសេកដេក | ខែ០៨-ខែ០២ | សន្ទូច មង លាន់ | ៥០ផ្លែ/៥០ម/ ១៥លាន់ | ១៥ |
| ៤ | អូរច្រវាល្មៀស | ខែ០៨-ខែ០២ | សន្ទូច មង លាន់ | ៥០ផ្លែ/៥០ម/ ១៥លាន់ | ១២ |
| ៥ | អាវែងអាក្រមោល | ខែ០៨-ខែ០២ | សន្ទូច មង លាន់ | ៥០ផ្លែ/៥០ម/ ១៥លាន់ | ១៤ |
| ៦ | ត្រពាំងគ្រួស | ខែ០១ដល់ខែ០៤ | សំណាញ់ មង | ៣៥ម/១វង់ | ៧ |
| ៧ | ត្រពាំងកក់ | ខែ០១ដល់ខែ០៤ | សំណាញ់ មង | ៣៥ម/១វង់ | ៩ |
| ៨ | ត្រពាំងតាប្រាក់ | ខែ០១ដល់ខែ០៤ | សំណាញ់ មង | ៣៥ម/១វង់ | ៦ |
| ៩ | ត្រពាំងទទឹងថ្ងៃ | ខែ០១ដល់ខែ០៤ | សំណាញ់ មង | ៣៥ម/១វង់ | ៨ |
| ១០ | ត្រពាំងបឹងនួន | ខែ០១ដល់ខែ០៤ | សំណាញ់ មង | ៣៥ម/១វង់ | ៥ |
| ១១ | ត្រពាំងគេដាំឈូក | ខែ០១ដល់ខែ០៤ | សំណាញ់ មង | ៣៥ម/១វង់ | ៧ |
| ១២ | ត្រពាំងស្មែងតាន់ | ខែ០១ដល់ខែ០៤ | សំណាញ់ មង | ៣៥ម/១វង់ | ៨ |
| ១៣ | ត្រពាំងចក | ខែ០១ដល់ខែ០៤ | សំណាញ់ មង | ៣៥ម/១វង់ | ៩ |
| ១៤ | ត្រពាំងស្មោញ | ខែ០១ដល់ខែ០៤ | សំណាញ់ មង | ៣៥ម/១វង់ | ៦ |
| ១៥ | ត្រពាំងក្រែង | ខែ០១ដល់ខែ០៤ | សំណាញ់ មង | ៣៥ម/១វង់ | ៧ |
| ១៦ | ត្រពាំងក្របៅ | ខែ០១ដល់ខែ០៤ | សំណាញ់ មង | ៣៥ម/១វង់ | ៨ |
| ១៧ | ត្រពាំងក្របីច្រើន | ខែ០១ដល់ខែ០៤ | សំណាញ់ មង | ៣៥ម/១វង់ | ៩ |

### គ.២.ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទ គឺជាការងារមួយដែលត្រូវទាមទារមានការគាំទ្របច្ចេកទេស និងថវិកា និងប្រើប្រាស់ពេលវេលាធ្វើការសិក្សាមួយច្បាស់លាស់ពីព្រោះថា ការកែលំអដែននេសាទសហគមន៍នេះវាពាក់ព័ន្ធជាមួយត្រីមេពូជ និងវារីសត្វគ្រប់ប្រភេទនៅក្នុងដែននេសាទនោះ។ ដូចនេះផងដែរ ក្នុងកិច្ចប្រជុំរវាងគណៈកម្មការ សមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន និងក្រុម សម្របសម្រួលរដ្ឋបាលជលផលថ្នាក់កណ្តាល បានពិនិត្យឃើញថាដែននេសាទនៅក្នុងសហគមន៍នេសាទដីក្រែងមានសភាពប្រែប្រួលខ្លះដែលបណ្តាលមកពីកក្តាមនុស្សនិងធម្មជាតិ។

ផែនការកែលំអដែននេសាទ ក្នុងគោលបំណង៖

- បង្កើនផលត្រី និងវារីសត្វគ្រប់ប្រភេទ និងជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ ។
- ធ្វើឲ្យសំបូរព្រៃលិចទឹកឲ្យនៅក្នុងដែននេសាទសហគមន៍។

ផែនការកែលំអដែននេសាទ នឹងត្រូវរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ឈ្មោះដែន នេសាទ | ទំហំ | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ដែនការស្តារខ្វែងស្ទឹងកំបុត | ១៥ ហត | ០,៥ ហត | ធ្វើការសិក្សា | ខែតុលា ២០១៩ | ខែធ្នូ ២០១៩ |
| | | | ការស្តារព្រៃក | ខែមករា ២០២០ | ខែធ្នូ ២០២០ |

### គ.៣ ផែនការរៀបចំកន្លែងអភិរក្ស

សហគមន៍នេសាទដីក្រែងបានសម្រេច ក្នុងការបង្កើតកន្លែងអភិរក្សចំនួន ០២ កន្លែង គឺ បឹងកំផែន និងកំពីងបឹង និងខ្វែងស្ទឹងកំបុត ដែលជាកន្លែងមានសក្តានុពលសម្រាប់អភិរក្សត្រីមេពូជ ។ ដូចនេះផងដែរ កន្លែងអភិរក្សបានធ្វើការគ្រប់គ្រងបន្ទាប់ពីសហគមន៍នេសាទដីក្រែង ត្រូវបានប្រកាសទទួលស្គាល់ដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ហើយកន្លែងអភិរក្សត្រីមេពូជទាំងពីរ នេះបង្កើតឡើងក្នុងគោលបំណង៖

- បង្កើនពូជត្រី និងសត្វគ្រប់ប្រភេទ
- ថែរក្សាការពារព្រៃលិចទឹក ដែលជាជម្រកនិងប្រភពចំណីរបស់ត្រីនិងសត្វ
- ផ្តល់ចំណេះដឹងដល់ប្រជាពលរដ្ឋ ឱ្យចេះស្រឡាញ់ថែរក្សា ការពារធនធានធម្មជាតិ និង
- ពិសេស ធនធានជលផល បរិស្ថាន និងចូលរួមលុបបំបាត់ការនេសាទខុសច្បាប់។

តាមការចុះអង្កេត និងពិនិត្យរបស់ក្រុមការងារ និងពិភាក្សាលើលក្ខណៈវិនិច្ឆ័យជាមួយគណៈកម្មការ និងសមាជិសហគមន៍នសាទដីក្រែង បានបញ្ជាក់ថា៖ កន្លែងអភិរក្សបឹងកំផែន និងកំពីងបឹង និងខ្វែងស្ទឹងកំបុត គឺជាកន្លែងសំខាន់បំផុតសម្រាប់ធ្វើការអភិរក្សដែលសមាជិសហគមន៍នសាទដីក្រែងមានសុច្ឆន្ទៈចង់ចូលរួមក្នុងការគ្រប់គ្រធនធានជលផល ដើម្បីធានានូវប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានជលផល និងជាប្រយោជន៍សម្រាប់តម្រូវការផលត្រីរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ ។

កន្លែងអភិរក្សត្រីមេពូជ ជាកត្តាចាំបាច់ដែលត្រូវរៀបចំកំណត់ព្រំប្រទល់ បោះបង្គលស៊ីម៉ងព្រំប្រទល់ ធ្វើប៉ាណូផ្សព្វផ្សាយ ក្តាខៀនព័ត៌មាន បិទផ្សាយបទបញ្ញត្តិផ្សេងសម្រាប់កន្លែងអភិរក្ស សាងសង់រោងយាមសម្រាប់ក្រុមល្បាតបំពេញការងារ មធ្យោបាយ និងសម្ភារៈផ្សេងទៀត។

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សនឹងត្រូវរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ឈ្មោះ/ទីតាំង | ទំហំ(ហិកតា) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្ដើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| បឹងកំផែន និងកំពីងបឹង | ៦០ | • ប្រភេទត្រីសំខាន់<br>• ប្រភេទសត្វស្លាប<br>• ប្រភេទពពួកល្មូន<br>• ព្រៃលិចទឹក | • ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ<br>• ធ្វើប៉ាណូផ្សព្វផ្សាយ<br>• សង់រោងយាម<br>• ចុះល្បាតជាប្រចាំ | ២០១៧ | ២០១៨ |
| ខ្វែងស្ទឹង កំបុត | ១៥ | • ប្រភេទត្រីសំខាន់<br>• ប្រភេទសត្វស្លាប<br>• ប្រភេទពពួកល្មូន<br>• ព្រៃលិចទឹក | • ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ<br>• ធ្វើប៉ាណូផ្សព្វផ្សាយ<br>• សង់រោងយាម<br>• ចុះល្បាតជាប្រចាំ | ២០១៧ | ២០១៩ |

### គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

នាទីព្រៃលិចទឹកមានគ្របដណ្ដប់លើដែននេសាទសហគមន៍ដីក្រែងមួយភាគធំ ដែលបាន ផ្ដល់នូវសក្ដានុពល និងសារៈប្រយោជន៍ជាច្រើនដល់ប្រភេទត្រី សត្វល្មូន ប្រភេទសត្វ និងវារីសត្វផ្សេងទៀត សម្រាប់ជាជម្រករស់នៅ បង្កកំណើតជាកូន និងជាចំណីផងដែរ។ ដូចនេះផែនការគ្រប់គ្រងព្រៃលិចទឹកក្នុងគោលបំណង៖

- ថែរក្សា ការពារព្រៃលិចទឹកឲ្យនៅគង់វង្សយូរអង្វែងក្មេងជំនាន់ក្រោយ។
- ទុកជាជម្រកត្រីនិងវារីសត្វគ្រប់ប្រភេទនិងជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិទប់ស្កាត់ការហូរច្រោះទឹករលក និងជារបាំងខ្យល់។
- បង្កើនទិន្នផលត្រីនិងពពួកសត្វមានជីវិតគ្រប់ប្រភេទឲ្យសំបូរឡើងដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍។

គណៈកម្មការ និងសមាជិកសហគមន៍នេសាទបានកំណត់ និងបែងចែកនាទីព្រៃលិចទឹកមានកន្លែង អភិរក្ស និងកន្លែងប្រើប្រាស់រំលោះ ដោយផ្អែកតាមផែនទីសហគមន៍នេសាទកន្លែងប្រើប្រាស់ព្រៃលិចទឹក ត្រូវអប់រំណែនាំដល់ប្រជាពលរដ្ឋឲ្យចេះកាប់រំលោះមែកដែលធ្វើយ៉ាងណាមិនឲ្យងាប់ដើម ដើម្បីយកមកប្រើប្រាស់ជាអុសចំអិនអាហារ ការកាប់រំលោះនេះធ្វើងលក្ខណៈវិលជុំជារៀងរាល់បីឆ្នាំម្ដងដើម្បីទុកឲ្យព្រៃមានលទ្ធភាពអាចដុះលូតលាស់ឡើងវិញបាន។

ដោយសារការយល់ដឹងពីសារៈសំខាន់នៃនាទីព្រៃលិចទឹក ប្រជាពលរដ្ឋមានការចូលរួមចំណែកយ៉ាងសកម្មក្នុងការគ្រប់គ្រងធនធានជលផលឲ្យប្រសើរឡើង ។

ខាងក្រោមនេះជាផែនការគ្រប់គ្រងនាទីព្រៃលិចទឹកក្នុងសហគមន៍ដីក្រែងមានដូចជា៖

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើដែលត្រូវការពារ | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្ដើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ដាំព្រៃលិចទឹកនៅខ្វែងស្ទឹងកំបុត | ៣ ហិកតា | រាំង ផ្ដោល ត្នួរ និង ច្រកែង ។ល។ | • ផ្សព្វផ្សាយពីផលប្រយោជន៍នៃការគ្រប់គ្រងព្រៃលិចទឹក | ១៥/១/១៧ | ១៨/១/១៨ |
| | | | • រៀបចំកូនឈើ | ១២/៥/១៧ | ៧/៦/១៨ |
| | | | • ពីធីដាំកូនឈើនិងដាក់ស្លាកសញ្ញាការពារ | ១០/៦/១៧ | ១៣/៦/១៨ |
| | | | • ថែរក្សា និងការពារ | ១៣/៦/១៧ | ៣០/៩/១៨ |
| ថែរក្សានិងការពារព្រៃលិចទឹក | ៨៤១ ហត | ព្រៃលិចទឹកគ្រប់ប្រភេទ | • ផ្សព្វផ្សាយផែនការគ្រប់គ្រងព្រៃលិចទឹក | ៣/១/១៩ | ៥/១/១៩ |
| | | | • ដាក់ស្លាកសញ្ញាការពារ | ៥/៣/១៩ | ១០/៣/១៩ |
| | | | • ត្រួតពិនិត្យ និងការពារ | ជាប្រចាំ | |

**គ.៥ ផែនការអភិវឌ្ឍន៍វារីវប្បកម្ម**

ក្រៅពីនេសាទត្រី ការចិញ្ចឹមត្រីជាមុខរបរបន្ទាប់ពីការធ្វើស្រែរបស់ប្រជានេសាទនៅក្នុងសហគន៍ដីក្រែងនេះជាទូទៅ ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទនេះ ច្រើនចិញ្ចឹមត្រីនៅតាមស្រះដែលការចិញ្ចឹមត្រីមានដូចជា៖ ត្រីរ៉ស់ ត្រីប្រា និងត្រីទីឡាបព្យា។ល ។

ការចិញ្ចឹមត្រីជាទិសដៅដ៏សំខាន់របស់វិស័យជលផល ក្នុងការបង្កើនត្រីសាច់សម្រាប់ហូបចុក របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងសម្រាប់នាំចេញទៅទីផ្សារអន្តរជាតិ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឲ្យមានការរីកចំរើន។ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ ២០១៦ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសលេខ ៣២៥ ប្រក កសក ស្តីពី ការគ្រប់គ្រងការចិញ្ចឹមត្រីរ៉ស់ ត្រីឆ្តោរ ដែលស្របនឹងតម្រូវការប្រជាពលរដ្ឋនៅមូលដ្ឋាន។ ដូចនេះផងដែរ សហគមន៍នេសាទដីក្រែងបានផ្តោតសំខាន់លើការចិញ្ចឹមត្រីតាមបែបដែលការចិញ្ចឹមត្រីមានដូចជា៖ ត្រីរ៉ស់ ត្រីប្រា និងត្រីទីឡាបព្យា ពីព្រោះសហគមន៍នេះស្ថិតក្នុងតំបន់បឹងទន្លេសាប។ ការអភិវឌ្ឍន៍វារីវប្បកម្មរបស់សហគមន៍នេសាទដីក្រែងក្នុងគោលបំណង៖

- បង្កើនត្រីសាច់សម្រាប់ហូបចុក របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- បង្កើនប្រាក់ចំណូលដែលជួយស្ទួយសេដ្ឋកិច្ចគ្រួសារ
- កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត។

ឆ្លើយតបនឹងទៅនឹងការពង្រីកការអភិវឌ្ឍន៍វារីវប្បកម្ម គណៈកម្មការ និងសមាជិកសហគមន៍នេសាទដីក្រែង បានរៀបចំផែនការអភិវឌ្ឍន៍ការចិញ្ចឹមត្រីដូចខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ (ក្បាល) | ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | ប្រមូលផល |
| ចិញ្ចឹមត្រីរ៉ស់តាមបច្ចេកទេសជាលក្ខណៈគ្រួសារតាមស្រះចំនួន ១៥គ្រួសារ | • ជ្រើសរើសសមាជិក<br>• បច្ចេកទេសចិញ្ចឹម<br>• ធ្វើស្រះចិញ្ចឹម<br>• ផ្តល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | ១៥ស្រះ ទំហំ១៥ម x ១០ម ត្រីរ៉ស | ត្រីរ៉ស់ | ៥,០០០ /គ្រួសារ | ១០/៥/១៧ | ៣០/៤/១៨ |
| ចិញ្ចឹមត្រីប្រាតាមបច្ចេកទេសជាលក្ខណៈគ្រួសារតាមស្រះ ចំនួន ១០ គ្រួសារ | • ជ្រើសរើសមាជិក<br>• បច្ចេកទេសចិញ្ចឹម<br>• ធ្វើស្រះចិញ្ចឹម<br>• ផ្តល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | ១០ ស្រះ ទំហំ១៥ម x ១០ ម ត្រីប្រា | ត្រីប្រា | ៦,០០០/ គ្រួសារ | ១២/៦/១៧ | ៣០/៣/១៨ |
| ចិញ្ចឹមត្រីទីឡាបព្យាតាមបច្ចេកទេសជាលក្ខណៈគ្រួសារក្នុងស្រះចំនួន ២ គ្រួសារ | • ជ្រើសរើស សមាជិក<br>• បច្ចេកទេសចិញ្ចឹម<br>• ធ្វើស្រះចិញ្ចឹម<br>• ផ្តល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | ២ ស្រះ ទំហំ ១០ម x ៨ ម ត្រីទីឡាបព្យា | ត្រីទីឡាបព្យា | ៧,០០០/ គ្រួសារ | ១២/៦/១៧ | ២៥/៤/១៨ |

### គ.៦.ផែនការថវិការទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ដោយឡែក គណៈកម្មការសហគមន៍បានដើរតួនាទីសំខាន់ក្នុងការស្វែងរកប្រាក់ចំណូល ពីប្រភពផ្សេងៗ ដូចជា៖ ភាគទានពីសមាជិកសហគមន៍ អង្គការដៃគូអភិវឌ្ឍន៍ សប្បុរសជន និងការធ្វើទស្សនកិច្ចរបស់ភ្ញៀវមកក្នុងសហគមន៍នេសាទ ។

ដូចនេះ ផែនការស្វែងរកថវិការសម្រាប់ទ្រង់សហគមន៍មានក្នុងតារាងខាងក្រោះ

| ប្រភេទចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូល(រៀល) |
|---|---|---|---|---|
| ភាគទានប្រចាំឆ្នាំពី សមាជិក សហគមន៍ | ប្រជុំផ្សព្វផ្សាយ និងបណ្ណភាគទាន | ២០១៧ | ២០១៩ | ១.៣៥១.៥០០ |
| ពីអ្នកនេសាទខាងក្រៅ | ចេញបណ្ណភាគទាន | ២០១៧ | ២០១៩ | ២.៥៦៥.០០០ |
| សប្បុរសជននិងអង្គការដៃគូអភិវឌ្ឍន៍ | • បង្កើតមុគរបរ<br>• ជាថវិកាផ្ទាល់ | ២០១៧ | ២០១៩ | ៦.០០០.០០០ |
| ក្រុមប្រឹក្សាឃុំ | ការពារធនធានធម្មជាតិ | ២០១៧ | ២០១៩ | ១.០០០.០០០ |

### គ.៧.ផែនការផ្សេងៗទៀត

#### គ.៧.១. ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ

